ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ២៧៣៦ កសក

# សេចក្តីជូនដំណឹង
## ស្តីពី
## វិធានការពង្រឹង ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃ និងជលផល

កន្លងមកក្នុងដំណើរការកំណែទម្រង់ស៊ីជម្រៅគ្រប់គ្រងធនធានធម្មជាតិក្នុងវិស័យព្រៃឈើ និងជលផល រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងជំរុញឱ្យមានការធ្វើវិសោធនកម្មច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ជាពិសេសការបែងចែកឡើងវិញនូវសមត្ថកិច្ចទទួលខុសត្រូវឱ្យបានច្បាស់លាស់រវាងស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ ព្រមទាំងរវាងថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាបាននូវការលើកកម្ពស់ប្រសិទ្ធភាព និងនិរន្តរភាពការគ្រប់គ្រងធនធានធម្មជាតិ។ ជាក់ស្តែង រាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងសារាចរណែនាំលេខ០៥ សរណន ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីវិធានការចាំបាច់នានាក្នុងការពង្រឹងការគ្រប់គ្រងធនធានធម្មជាតិដែលបានផ្តល់សិទ្ធិអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្តដោយផ្ទាល់នៅថ្នាក់មូលដ្ឋាន។

ដើម្បីឆ្លើយតបទៅនឹងខ្លឹមសារនៃលិខិតបទដ្ឋានគតិយុត្តខាងលើ និងអនុវត្តតាមបទបញ្ជាដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងពិធីបិទសន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទូទាំងប្រទេសប្រចាំឆ្នាំ២០២១ និងទិសដៅអនុវត្តឆ្នាំ២០២២ នាថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ក្នុងការពង្រឹងការគ្រប់គ្រងធនធានព្រៃឈើ សត្វព្រៃ និងធនធានជលផលឱ្យបានល្អប្រសើរនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមរដ្ឋបាលថ្នាក់ក្រោមជាតិចូលរួមអនុវត្តនូវវិធានការចាំបាច់ជាក់ស្តែងមួយចំនួនដូចខាងក្រោម៖

១-ដឹកនាំ និងសម្របសម្រួលកម្លាំងមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីធានាបាននូវការប្រើប្រាស់កម្លាំងសរុប និងមធ្យោបាយចាំបាច់នានាក្នុងការថែរក្សាការពារធនធានព្រៃឈើ សត្វព្រៃ និងធនធានជលផលក្នុងដែនសមត្ថកិច្ចរបស់ខ្លួនប្រកបដោយឆន្ទៈម្ចាស់ការ និងស្មារតីទទួលខុសត្រូវ។

២-ត្រូវទប់ស្កាត់ការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើ និងដីព្រៃលិចទឹក ដោយចាត់វិធានការគ្រប់គ្រង ត្រួតពិនិត្យនូវការធ្វើសន្និធិ ការធ្វើចរាចរ និងការកែច្នៃផល អនុផលព្រៃឈើគ្រប់ប្រភេទ ព្រមទាំងទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផលគ្រប់ប្រភេទផងដែរ។

៣-ក្នុងករណីប្រទះឃើញបទល្មើសជាក់ស្តែង ត្រូវចាត់វិធានការទប់ស្កាត់ និងបង្ក្រាបជាបន្ទាន់ តាមដែនសមត្ថកិច្ចរៀងៗខ្លួន ចៀសវាងទុកឱ្យបទល្មើសទាំងនោះរីករាលដាលកាន់តែធំ និងពិបាកក្នុងការដោះស្រាយ។ ប្រសិនបើបទល្មើសមានទ្រង់ទ្រាយធំមានលក្ខណៈស្មុគស្មាញ ត្រូវរាយការណ៍ និងសុំអន្តរាគមន៍ជាបន្ទាន់មកក្រសួង-ស្ថាប័ននៅថ្នាក់ជាតិ ដើម្បីមានវិធានការ និងរួមគ្នាដោះស្រាយតាមនីតិវិធីជាធរមាន។

៤-ក្នុងករណីមានបទល្មើសធ្ងន់ធ្ងរ ក្រសួង-ស្ថាប័នថ្នាក់ជាតិនឹងចាត់ថ្នាក់ដឹកនាំ រួមជាមួយអង្គភាពជំនាញចុះសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីចាត់វិធានការទប់ស្កាត់ និងបង្ក្រាបឱ្យបានទាន់ពេលវេលា។ ករណី



អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣ ២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

មិនអាចដោះស្រាយបាន ក្រសួង-ស្ថាប័ននៅថ្នាក់ជាតិនឹងស្នើសុំអនុសាសន៍ដឹកនាំពីប្រមុខរាជរដ្ឋាភិបាល ដើម្បីចាត់វិធានការតាមផ្លូវច្បាប់ជាធរមាន។

៥- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងចាត់ថ្នាក់ដឹកនាំរៀបចំកិច្ចប្រជុំត្រួតពិនិត្យ វាយតម្លៃលើការអនុវត្ត និងរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល អំពីលទ្ធផលទទួលបានជាប់ជាប្រចាំរៀងរាល់ចុងខែ។

ទទួលបានសេចក្តីជូនដំណឹងនេះ សូម ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ជាប្រធានគណៈបញ្ជាការឯកភាពរាជធានី-ខេត្ត ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ អង្គារ ៤ កើត ខែ ចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ២០២២

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**ចម្លងជូន៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងយុត្តិធម៌
- ដើម្បីជូនជ្រាប -
-អគ្គាធិការដ្ឋាន
-រដ្ឋបាលព្រៃឈើ
-មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត
- ដើម្បីសហការ និងអនុវត្ត -
-ឯកសារ កាលប្បវត្តិ